ប្រការ ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទីតិសម្បទា និងអភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បណ្តាស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី ២ |
| --- | --- |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

# III - ការងារបណ្តាក្រសួង

## ១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាស ០១០ ប្រក.សហវ

ស្តីពីការបង្កើតគណៈកម្មការដោះស្រាយវិវាទ លើការតវ៉ាអំពីអធិការកិច្ចនិតិវិធីមុនពេលផ្ទុក

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកាឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រុមហ៊ុន (SGS) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការធ្វើអធិការកិច្ចមុនពេលផ្ទុក ។
- បានឃើញប្រកាសលេខ ៣២១ ប្រកសហវ.គរ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការ អនុវត្តសេវាអធិការកិច្ចមុនពេលផ្ទុក សំរាប់នាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញលិខិតស្តីពីការចាត់មន្ត្រីចូលរួមក្នុងគណៈកម្មការដោះស្រាយវិវាទ លើការតវ៉ាអំពីអធិការកិច្ចទំនិញមុនពេលផ្ទុក លេខ ១០០១.៩៥ កអក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លេខ២៣៩១ ពណមទ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ របស់ក្រសួង ពាណិជ្ជកម្ម លេខ ៦ សភពកព ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់សភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងលេខ ១៦៦៦.៩៥ គរ ចុះ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ទីចាត់ការគយ និងរដ្ឋាករ ។
- យោងតាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការដោះស្រាយវិវាទលើការតវ៉ាអំពីអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) មួយដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២-ឯកឧត្តម **ជា ម៉េងឈាង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៣-លោក **សារ៉ាត់ ខាន់** អគ្គនាយកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤-លោក **ឆេង សារឿន** នាយកកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក

៥-លោក **អ៊ិត ចិរ៉ាឧត្ដម** ទីប្រឹក្សាប្រចាំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៦-លោក **លឹម សុគន្ធា** ទីប្រឹក្សា នៃសភាពាណិជ្ជកម្ម សមាជិក

៧-លោក **សៀង ឈុនឡើ** នាយករងទីចាត់ការគយ និងរដ្ឋាករ សមាជិក

៨-លោក **ជា អៀវម៉េង** មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខាធិការ

**ប្រការ ២** : គណៈកម្មការដោះស្រាយវិវាទលើការតវ៉ាអំពីអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) មាន ភារកិច្ចដោះស្រាយរាល់វិវាទទាំងឡាយដែលកើតមានឡើង រវាងអ្នកនាំចូល និងក្រុមហ៊ុនអធិការកិច្ច (SGS) ដោយត្រូវសំរេចលើការវិវាទនេះក្នុង រយៈពេល ០១ ខែ យ៉ាងយូរ ក្រោយពីបាន ទទួលសំណុំលិខិតតវ៉ារបស់អ្នកនាំចូល ។

**ប្រការ ៣ :** ឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

**គាត ឈន់**

* * *

## ២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ប្រកាស**

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាស ០៥២ ពណ.ចល.ប្រក**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកាឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជ រដ្ឋាភិបាលកម្ពុជា ។
- ពិនិត្យលើការងាររបស់ចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការចាត់តាំងពិព័រណ៍ពាណិជ្ជកម្មមួយរបស់ក្រសួង ដើម្បី រៀបចំតុបតែង ផ្សព្វផ្សាយតាំង និងលក់ទំនិញដែលរួមមានសមាសភាព